ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

NCAC
មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តកការផ្នែកពាណិជ្ជកម្ម
NATIONAL COMMERCIAL ARBITRATION CENTRE

លេខ៖ ០១០ - ម.ជ.ម.

**សូមគោរពជូន**

**លោកមជ្ឈត្តករ អ៊ុច ខុន្ធី**

កម្មវត្ថុ៖ ស្តីពីការចូលរួមក្នុងការពិគ្រោះយោបល់លើវិធានស្តីពីសន្ធានកម្ម និងក្រមសីលធម៌របស់សន្ធានកររបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តកការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.)

ដូចសេចក្តីមានចែងក្នុងកម្មវត្ថុខាងលើ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តកការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) មានសេចក្តីសោមនស្សរីករាយក្នុងការអញ្ជើញ **លោកមជ្ឈត្តករ** ចូលរួមក្នុងការពិគ្រោះយោបល់ជាសាធារណៈទៅលើវិធានស្តីពីសន្ធានកម្មរបស់ ម.ជ.ម. ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០២៣ នៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ (Hyatt Regency Phnom Penh)។

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តកការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) សូមជម្រាបផងដែរថា ដោយមានការគាំទ្រពីសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ម.ជ.ម. នឹងរៀបចំវេទិកាពិគ្រោះយោបល់ជាសាធារណៈ ដោយមានការអញ្ជើញចូលរួមពីក្រសួង ស្ថាប័ន ការិយាល័យមេធាវី សមាគមន៍ និងភាគីពាក់ព័ន្ធនានា ដើម្បីពិភាក្សា និងផ្តល់ជាមតិកែលម្អទៅលើវិធានស្តីពីសន្ធានកម្ម និងក្រមសីលធម៌របស់សន្ធានកររបស់ ម.ជ.ម. ។

ការពិគ្រោះយោបល់ជាសាធារណៈជាធាតុសំខាន់ក្នុងការសម្រេចបាននូវវិធាន និងក្រមសីលធម៌របស់សន្ធានករប្រកបដោយតម្លាភាព និងមានប្រសិទ្ធភាព ដើម្បីស្វែងយល់ និងផ្តល់ជាគំនិតពីសំណាក់អ្នកចូលរួម ក៏ដូចជាស្ថាប័នពាក់ព័ន្ធទៅលើបទប្បញ្ញត្តិ និងនីតិវិធីនៃសេចក្តីព្រាងនៃវិធានស្តីពីសន្ធានកម្ម ការកំណត់តម្លៃសេវា និងក្រមសីលធម៌របស់សន្ធានករ ដើម្បីជំរុញការប្រើប្រាស់យន្តការដោះស្រាយវិវាទក្នុងវិស័យពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា ។ ម.ជ.ម. រីករាយនឹងឆ្លើយតបរាល់សំណួរអំពីការពិគ្រោះយោបល់ជាសាធារណៈ។ ម.ជ.ម. សង្ឃឹមយ៉ាងមុតមាំថា **លោកមជ្ឈត្តករ** នឹងចូលរួម ដើម្បីភាពប្រសើរឡើងនៃការដោះស្រាយវិវាទពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ម.ជ.ម. សូមភ្ជាប់ជាមួយឯកសារពាក់ព័ន្ធសម្រាប់ការពិនិត្យមើលទុកជាមុន៖ (១) វិធានស្តីពីសន្ធានកម្ម និងតារាងកម្រៃសេវា និង (២) ក្រមសីលធម៌របស់សន្ធានករ។


ជាន់ទី៣៧ អគារ GIA Tower ផ្លូវសុភមង្គល សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
37th Floor, GIA Tower, Street Sopheak Mongkol, Tonle Bassac, Chamkamorn, Phnom Penh, Cambodia.
T: +855 96 888 5333 | E: info@ncac.org.kh | W: www.ncac.org.kh

តាមរយៈព័ត៌មានដែលបានជម្រាបជូនខាងលើ សូម **លោកមជ្ឈត្តករ** ចូលរួមការពិគ្រោះយោបល់ជាសាធារណៈនេះ តាមរយៈការចុះឈ្មោះលើតំណ http://bit.ly/mediation-rules-public-consultation ។

សូម **លោកមជ្ឈត្តករ** ទទួលនូវការគោរព អំពីយើងខ្ញុំ។

ថ្ងៃច័ន្ទ ៨រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

*រាជធានីភ្នំពេញ*, ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០២៣

**មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម**

**ប្រធាន**

មជ្ឈត្តករ **សាន គីរី**

ឯកសារភ្ជាប់៖

- វិធានស្តីពីសន្ទានកម្ម
- ក្រមសីលធម៌របស់សន្ទានករ